ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ០៩៣៣...ឧវអន.អសឧ.សរណ

# សេចក្តីជូនដំណឹង
## ស្តីពី
## កម្មវិធី «ពានរង្វាន់ឧស្សាហកម្មបៃតងកម្ពុជា ឆ្នាំ២០២៤»

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សូមជូនដំណឹងដល់ម្ចាស់រោងចក្រ សហគ្រាស និងសិប្បកម្មទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាជ្រាបថា ដើម្បីជាការទទួលស្គាល់ លើកទឹកចិត្ត និងផ្តល់រង្វាន់ដល់កិច្ចខិតខំប្រឹងប្រែងប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងបច្ចេកវិទ្យាថ្មីៗ ឈានទៅរកការអភិវឌ្ឍឧស្សាហកម្មប្រកបដោយចីរភាព និងរួមចំណែកដល់ការកាត់បន្ថយ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ ក្រសួងនឹងរៀបចំកម្មវិធី **«ពានរង្វាន់ឧស្សាហកម្មបៃតងកម្ពុជា ឆ្នាំ២០២៤»** ដែលនឹងប្រព្រឹត្តទៅនៅខែវិច្ឆិកា **ឆ្នាំ២០២៤**ខាងមុខនេះ។ អត្ថប្រយោជន៍ទទួលបានពីការចូលរួមកម្មវិធីនេះមាន៖ ទទួលបានពានរង្វាន់ថ្នាក់ជាតិ(មាស ប្រាក់ សំរិទ្ធ) វិញ្ញាបនបត្រជ័យលាភី ការផ្សព្វផ្សាយជាសាធារណៈ កេរ្តិ៍ឈ្មោះជាគំរូដល់រោងចក្រ សហគ្រាស និងសិប្បកម្មផ្សេងទៀត។

លោក-លោកស្រីម្ចាស់រោងចក្រ សហគ្រាស និងសិប្បកម្ម ដែលមានបំណងចូលរួមក្នុងកម្មវិធីនេះ អាចបំពេញពាក្យសុំចូលរួមតាមរយៈតំណភ្ជាប់ https://forms.gle/D36BxDGCraTRWxwb7 ឬទាញយកពាក្យសុំចូលរួមតាមរយៈ https://drive.google.com/file/d/1ftiB0miYQsiOalG7tFbfOudUe4EBOuiC/view?usp=sharing ឬលោក-លោកស្រីក៏អាច Scan QR Code ខាងក្រោម។

ពាក្យសុំចូលរួមនឹងចាប់ទទួលពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ តាមរយៈអ៊ីមែល misti.gia@gmail.com ឬបំពេញពាក្យសុំតាម Online ដែលមាន QR Code ខាងក្រោម។

ថ្ងៃ សុក្រ ១៤រោច ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែកក្កដា ឆ្នាំ២០២៤

*សូម Scan QR Code៖*

*ដើម្បីចូលរួមChannel Telegram*

*ដើម្បីបំពេញពាក្យសុំOnline*

*ដើម្បីទាញយកពាក្យសុំជាPDF*

*បញ្ជាក់៖*
*ដើម្បីប្រើប្រាស់ និងទាញយកពាក្យសុំតាមរយៈតំណភ្ជាប់នេះ សូមប្រើ Gmail Account ដែលមានស្រាប់ ឬបង្កើត Gmail Account ថ្មីជាមុនសិន។*

ព័ត៌មានលម្អិតសូមទំនាក់ទំនង៖
- លោក ឆេង ភីរុណ : ០១២ ៧០៤ ២៣១
- លោក ចុង ប៊ូ : ០១២ ៨៣៥ ២៦០
- លោកស្រី លី ចាន់ថុល : ០៩៩ ៥៥៦ ៦៨៩